**សុន្ទរកថារបស់ ឯកឧត្តម គូម៉ាម៉ារូ យូជិ**
**ឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាពរបស់ប្រទេសជប៉ុន**
**ប្រចាំព្រះរាជាណាចក្រកម្ពុជា**
**ថ្លែងក្នុងពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការសមិទ្ធផល**
**"គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតនៅខេត្តបាត់ដំបង និងខេត្តកំពង់ចាម"**
**ខេត្តបាត់ដំបង, ថ្ងៃទី២១ ខែកក្កដា ឆ្នាំ ២០១៦**

- សូមក្រាបថ្វាយបង្គំ ព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ ជាទីគោរពសក្ការៈ
- សូមគោរព **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- សូមគោរព សម្តេចក្រឡាហោម ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សូមគោរព ឯកឧត្តម **ចម ប្រសិទ្ធ** ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- សូមគោរព ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី
- សូមគោរព ឯកឧត្តម ច័ន្ទ សុផល អភិបាលនៃគណអភិបាលខេត្តបាត់ដំបង
- សូមគោរព ឯកឧត្តម លន់ លឹមថៃ អភិបាលនៃគណអភិបាលខេត្តកំពង់ចាម
- សូមគោរព ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយស និងអស់លោក លោកស្រីទាំងអស់!

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែងដែលបានចូលរួមពិធីសម្ពោធដាក់ឲ្យប្រើប្រាស់ជាផ្លូវការរោងចក្រប្រព្រឹត្តកម្មទឹកស្អាតចំនួនពីរក្រោម "គម្រោងពង្រីកប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតក្នុងខេត្តបាត់ដំបង និងខេត្តកំពង់ចាម" ជាមួយនឹងវត្តមានដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា។

គម្រោងជំនួយឥតសំណងរបស់រដ្ឋាភិបាលជប៉ុនក្នុងចំនួនទឹកប្រាក់ ៣,៣៥៥លានយ៉េននេះ បានអនុវត្តនូវការសាងសង់រោងចក្រប្រព្រឹត្តកម្មទឹកស្អាត ដែលអាចផ្គត់ផ្គង់ទឹកស្អាតបានចំនួន២២,០០០ម៣ ក្នុងមួយថ្ងៃសម្រាប់បាត់ដំបង និង១១,៥០០ ម៣ ក្នុងមួយថ្ងៃសម្រាប់កំពង់ចាម ជាមួយនឹងការរៀបចំប្រព័ន្ធចែក

ចាយដល់គ្រួសារនិមួយៗ គិតជាប្រវែងសរុបសម្រាប់តំបន់ទាំងពីរ មានប្រវែងលើសពី១២០គីឡូម៉ែត្រ។ ប្រព័ន្ធនេះមានសមត្ថភាពក្នុងការផ្គត់ផ្គង់ទឹកស្អាតមានសុវត្ថិភាពប្រកបដោយស្ថេរភាព ជូនដល់ប្រជាជនរស់នៅក្នុងបាត់ដំបងប្រមាណជាង ៨១,០០០នាក់ និងប្រមាណជាង ៣៧,០០០នាក់ សម្រាប់ប្រជាជនរស់នៅក្នុងកំពង់ចាម ដើម្បីចូលរួមជាចំណែកមួយយ៉ាងធំធេងក្នុងការជួយសម្រួលដល់ជីវភាពរស់នៅ និងការធ្វើអោយប្រសើរឡើងនូវបរិស្ថានអនាម័យរបស់ប្រជាជនរស់នៅក្នុងតំបន់ទាំងពីរ។

គម្រោងខ្នាតធំបែបនេះ នឹងមិនអាចសម្រេចបានឡើយប្រសិនបើគ្មានការចូលរួមជាកំលាំងយ៉ាងអស់ពីកាយចិត្តពីសំណាក់ភាគីជាច្រើនដែលបានចូលរួមក្នុងដំណើរការគម្រោងនេះ ដូចជាក្រុមហ៊ុននីហុន ស៊ូអ៊ីដូ ការិយាល័យទឹកស្អាត និងទឹកស្អុយ របស់ទីក្រុងគីតាគ្យូស៊ូ និងក្រុមហ៊ុនស៊ីធីអាយ វិស្វកម្មអន្តរជាតិដែលបានចូលរួមជាទីប្រឹក្សាបច្ចេកទេសគម្រោង រួមជាមួយនឹងកិច្ចសហប្រតិបត្តិការពីក្រុមហ៊ុនសំណង់គូបូតាដែលជាអ្នកសាងសង់ ព្រមទាំងសមាជិក សមាជិកា របស់JICAទាំងអស់ផងដែរ។ ឈ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅជូនដល់អ្នកទាំងអស់គ្នា ហើយខ្ញុំគិតថា ដំណើរការអនុវត្តគម្រោងនេះពិតជាបានជួបប្រទះជាមួយនឹងការលំបាកជាច្រើន ក៏ប៉ុន្តែខ្ញុំបានទទួលដំណឹងថា ក្នុងអំឡុងពេលដំណើរការសាងសង់ គ្មានករណីគ្រោះថ្នាក់មនុស្សហេតុណាមួយបានកើតឡើងនោះទេ ទាំងនេះគឺជាសមិទ្ធផលមួយដ៏អស្ចារ្យកើតឡើងចេញពីការខិតខំប្រឹងប្រែងដើម្បីធានាអោយបាននូវបរិស្ថានសុវត្ថិភាពមួយរបស់អ្នកទាំងអស់គ្នា។

រោងចក្រប្រព្រឹត្តកម្មទឹកស្អាតនេះមានប្រើប្រាស់បច្ចេកទេសជប៉ុនជាច្រើនដូចជា ប្រព័ន្ធចម្រោះទឹកស្អាត និងម៉ាស៊ីនប៉ូមទឹកអគ្គិសនីជាដើមដែលជាផលិតផលរបស់ក្រុមហ៊ុនជប៉ុន។ ខ្ញុំសង្ឃឹមថា ផលិតផលនិងបច្ចេកទេសរបស់ជប៉ុន នឹងត្រូវបានប្រើប្រាស់បន្តទៀតសម្រាប់គម្រោងពាក់ព័ន្ធនឹងទឹក ដែលនឹងត្រូវបានអនុវត្តទៅថ្ងៃមុខ នៅក្នុងប្រទេសកម្ពុជា ព្រោះខ្ញុំគិតថាវានឹងមានប្រយោជន៍ក្នុងការជួយអោយគម្រោងនានាទទួលបានជោគជ័យ ព្រមទាំងជួយធានានូវសុវត្ថិភាព និងទំនុកចិត្តដល់ប្រជាជនផងដែរ។

តាំងពីឆ្នាំ១៩៩០មក ប្រទេសកម្ពុជាសម្រេចបាននូវការអភិវឌ្ឍន៍គួរឲ្យកត់សម្គាល់ក្នុងវិស័យប្រព័ន្ធទឹកស្អាតដោយមានរាជធានីភ្នំពេញជាអ្នកនាំមុខ។ ស្ថានភាពផ្គត់ផ្គង់ទឹកស្អាតនៅទីប្រជុំជននានាក្នុងប្រទេសកម្ពុជាទទួលបានការកែលម្អជាច្រើន តាមរយៈការអនុវត្តជាបន្តបន្ទាប់នូវជំនួយហិរញ្ញប្បទានឥតសំណងកម្ចីឥណទាន រួមទាំងកិច្ចសហប្រតិបត្តិការបច្ចេកទេសពីរដ្ឋាភិបាលជប៉ុន។ យុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ

២០១៤ - ២០១៨ របស់កម្ពុជាបានកំណត់គោលដៅធំមួយគឺ ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនគ្រប់រូបនៅតាមទីប្រជុំជនទាំងអស់អោយបានត្រឹមឆ្នាំ ២០២៥ ហើយខ្ញុំសង្ឃឹមថា ការរៀបចំប្រព័ន្ធសំខាន់ៗផ្សេងទៀតនឹងត្រូវបានប្រព្រឹត្តិទៅនាថ្ងៃមុខដើម្បីឆ្ពោះទៅកាន់គោលដៅនេះ។

ជាទីបញ្ចប់ ខ្ញុំសូមសម្តែងការអេបអរសារទរចំពោះទំនាក់ទំនងកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និទ្ធជាយូរណាស់មកហើយរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុនក្នុងវិស័យប្រព័ន្ធទឹកស្អាត ហើយខ្ញុំក៏សង្ឃឹមយ៉ាងមុតមាំផងដែរថាទំនាក់ទំនងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសកម្ពុជា និងប្រទេសជប៉ុននឹងកាន់តែមានភាពស៊ីជម្រៅបន្ថែមទៀតសម្រាប់វិស័យទូលាយជាងនេះទៅថ្ងៃមុខ។

**សូមអរគុណ។**